ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ចន្ទ ១ រោច ខែ ពិសាខ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២២*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃការវាយតម្លៃបឋមលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា
## របស់ក្រុមបេសកកម្ម នៃមូលនិធិរូបិយវត្ថុអន្តរជាតិ

នាព្រឹកថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០២២ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បានដឹកនាំកិច្ចប្រជុំស្តីពីលទ្ធផល នៃការវាយតម្លៃបឋមលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា ដោយមានការអញ្ជើញចូលរួមដោយផ្ទាល់របស់ **ឯកឧត្តម Kenji Okamura, IMF Deputy Managing Director** និងក្រុមការងារបេសកកម្មនៃមូលនិធិរូបិយវត្ថុអន្តរជាតិ (Staff Visit) សម្រាប់កម្ពុជា ឆ្នាំ ២០២២ ដែលដឹកនាំដោយលោក Alasdair Scott ប្រធានក្រុមបេសកកម្មរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ព្រមទាំងមានការចូលរួមពីលោក Yasuhisa Ojima តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំនៅកម្ពុជា និងថ្នាក់ដឹកនាំក្រសួងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញចូលរួមរបស់**ឯកឧត្តម Kenji Okamura** ក្នុងបេសកកម្ម នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (Staff Visit) សម្រាប់កម្ពុជា ឆ្នាំ ២០២២ ហើយបានលើកឡើងពីសារសំខាន់នៃបេសកកម្ម នៃមូលនិធិរូបិយវត្ថុអន្តរជាតិ នាពេលនេះ ក្នុងការពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ក្នុងបរិការណ៍នៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់ និងភាពតានតឹងនៃភូមិសាស្ត្រនយោបាយ ដូចជា វិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលបាននិងកំពុងបង្កផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលលើបណ្តាប្រទេសនានាក្នុងសកលលោក ។

ចំពោះលទ្ធផលនៃការវាយតម្លៃមកលើស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈកម្ពុជា, លោក Alasdair Scott បានជម្រាបជូនពីការវាយតម្លៃសេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២២ ថានឹងសម្រេចបានក្នុងរង្វង់ ៥,១% ដូចគ្នានឹងការព្យាករកាលពីខែមុន ដោយសារការបន្តងើបឡើងវិញលឿននៃសកម្មភាពសង្គម-សេដ្ឋកិច្ច និងតម្រូវការខាងក្រៅ ខណៈដែលហានិភ័យមួយចំនួនអាចនឹងប៉ះពាល់ដល់កំណើននេះ រួមមាន ការកើនឡើងខ្ពស់នៃអត្រាអតិផរណា, ការបន្តអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន, ការថមថយនៃសេដ្ឋកិច្ចចិន, និងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍លឿនជាងការរំពឹងទុក ។ ជាមួយគ្នានេះ, សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ ២០២៣ ត្រូវបានវាយតម្លៃឡើងវិញថានឹងមានកំណើនខ្ពស់ជាងការព្យាករកាលពីពេលមុនក្នុងអត្រា ៦,២% គាំទ្រដោយនិន្នាការល្អជាងការរំពឹង

ទុកនៃវិស័យទេសចរណ៍ ។ ក្រុមការងារមូលនិធិរូបិយវត្ថុអន្តរជាតិ ក៏បានសំដែងនូវការកោតសរសើរខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងក្នុងទិដ្ឋភាពសង្គម និងសេដ្ឋកិច្ច ព្រមទាំងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានយ៉ាងសកម្ម និងទាន់ពេលវេលា ជាពិសេស វឌ្ឍនភាពប្រកបដោយផ្លែផ្កានៃយុទ្ធនាការចាក់វ៉ាក់សាំងរបស់កម្ពុជា ។ ក្រុមការងារ ក៏បានសំដែងឆន្ទៈយ៉ាងមោះមុតក្នុងការគាំទ្រកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងរៀបចំកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ ២០២២ ខាងមុខ និងត្រៀមខ្លួនរួចជាស្រេច ក្នុងការផ្តល់ការគាំទ្របន្ថែមទៀតដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងទិដ្ឋភាពជាជំនួយបច្ចេកទេស និងការផ្តល់អនុសាសន៍គោលនយោបាយចាំបាច់នានា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានធ្វើការវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងាររបស់ក្រុមការងារ សម្រាប់កម្ពុជា ឆ្នាំ២០២២ និងបានកត់សម្គាល់ពីភាពប្រហាក់ប្រហែលគ្នានៃការវាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលខ្លី និងមធ្យម ។ ដោយបរិបទបច្ចុប្បន្ននៃភាពមិនប្រាកដប្រជាខ្ពស់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានស្នើឱ្យក្រុមការងារនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ពិនិត្យមើលលើបញ្ហាសំខាន់ៗចំនួន ៣ សម្រាប់ក្រុមការងារបេសកកម្ម Article IV ដែលគ្រោងនឹងរៀបចំក្នុងរយៈពេលប៉ុន្មានខែខាងមុខ រួមមាន÷ ១. ការកើនឡើងនៃអត្រាអតិផរណាដោយសារសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែន និងឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា ជាពិសេស លើវិស័យកសិកម្ម, ២. បញ្ហានៃការកើនឡើងយ៉ាងឆាប់រហ័សនៃឥណទានក្នុងវិស័យឯកជន និងហានិភ័យលើសេដ្ឋកិច្ច ជាពិសេសសម្រាប់វិស័យសំណង់ និងអចលនទ្រព្យ, និង ៣. ការពិនិត្យឡើងវិញនៃយុទ្ធសាស្ត្រប្រមូលចំណូល និងប្រភពហិរញ្ញប្បទានសម្រាប់ដំណាក់កាលបន្ទាប់ ។

ឆ្លៀតក្នុងឱកាសនេះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះ មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងការចូលរួមចំណែកដល់ភាពជោគជ័យនៃកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន (AFMGM) ព្រមទាំងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូកបី ។ កម្ពុជា ទន្ទឹងរង់ចាំការបន្តគាំទ្រ និងការរួមចំណែកសម្រាប់ភាពជោគជ័យនៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនាពេលខាងមុខ រួមទាំង "2nd ASEAN Global Dialogue" ក្រោមប្រធានបទ "Post COVID-19 Comprehensive Recovery" ដែលនឹងប្រព្រឹត្តទៅនៅចុងឆ្នាំនេះ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាថ្មីម្តងទៀតចំពោះមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានបន្តផ្តល់ជាជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលដល់មន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងការវាយតម្លៃលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការផ្តល់អនុសាសន៍គោលនយោបាយល្អៗ និងចាំបាច់ ក្នុងបរិបទនៃភាពមិនប្រាកដប្រជាកាន់តែខ្ពស់នាពេលបច្ចុប្បន្ន ដើម្បីជួយតម្រង់ទិសការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែប្រសើរឡើង ក្នុងដំណាក់កាលស្តារសេដ្ឋកិច្ចឡើងវិញក្នុង និងក្រោយបរិការណ៍កូវីដ-១៩ ។

៙៙៙✱๛๛๛